**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

# កិច្ចការស្រាវជ្រាវ

## បទល្មើស (សញ្ញាណ និងចរិតលក្ខណៈ)


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ

-**យ៉ំ វឌ្ឍនា** -**ដាម យុនម៉ាលី**

-**ហែម ម៉ូលីកា** -**អ៊ិត សោភា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ស៊ិន រិទ្ធ**


ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ** ឆ្នាំចូលសិក្សា ២០១៣

ជំនាញ **នីតិឯកជន** ជំនាន់ទី១០ ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៤


**រក្សាសិទ្ធិដោយ** Khmer Famous

# មាតិកា


**សេចក្តីផ្តើម................................................................................................១**

**ផ្នែកទី១៖សញ្ញាណនៃបទល្មើស.........................................................................២**

១. អំពើ..........................................................................................................២

២. ព្យសនកម្ម ..................................................................................................៣

៣.ទណ្ឌកម្ម ......................................................................................................៤

៤. ច្បាប់ ..........................................................................................................៥

**ផ្នែកទី២៖ចរិកលក្ខណៈនៃបទល្មើស ....................................................................៦**

១. បុគ្គលិកលក្ខណៈបុគ្គល ...................................................................................៦

១.១. ឥទ្ធិពលនៃសរីរៈតពូជ ឬ ការសិក្សាពីតំណពូជ ..................................................៧

១.២. ឥទ្ធិពលនៃស្ថានភាពខាងក្នុងរាងកាយបុគ្គល ..................................................៧

២. ការវិវត្តន៍របស់សង្គម ......................................................................................៨

២.១. កត្តាសង្គម ..................................................................................................៨

២.២. កត្តានៃស្ថានភាពសេដ្ឋកិច្ច ...............................................................................៩

២.៣.កត្តានៃស្ថានភាពនយោបាយ ........................................................................ ១០

២.៤. កត្តានៃសង្គ្រាម........................................................................................ ១០

២.៥. កត្តាស្ថានភាពអប់រំ ................................................................................... ១១

២.៦. កត្តាប្រព័ន្ធច្បាប់ ....................................................................................... ១១

២.៧. កត្តាស្ថាប័នការពារច្បាប់............................................................................. ១២

២.៨. កត្តាទីតាំងភូមិសាស្ត្រ ................................................................................. ១២

**សេចក្តីសន្និដ្ឋាន.............................................................................................១៣**

**ឯកសារយោង ...............................................................................................១៤**

# សេចក្តីផ្តើម

ការរស់នៅក្នុងសង្គមទោះជាសង្គមគ្រួសារក្តី សង្គមមនុស្សក្តី សង្គមជាតិក្តី រមែងតែងជួបប្រទះនូវបញ្ហានិងវិបត្តិគ្រាន់តែតិចឬច្រើន ធំឬតូច តែប៉ុណ្ណោះ ។ ដំណោះស្រាយនៃបញ្ហាទាំងឡាយវាអាស្រ័យទៅនឹងកម្រិតនៃការយល់ដឹងនិងការត្រិះរិះពិចារណារបស់មនុស្សម្នាក់ៗ ។ ការគិតនិងការពិចារណារបស់មនុស្សគ្រប់រូបមិនដូចគ្នានោះទេ ហេតុនេះនៅពេលជួបនូវបញ្ហាការដោះស្រាយនិងការសម្រេចចិត្តរបស់មនុស្សម្នាក់ៗក៏រមែងមានភាពខុសៗគ្នាដែរ ។ អ្នកខ្លះដោះស្រាយបញ្ហាដោយសន្តិវិធីប្រកបដោយវិចារណញ្ញាណ ខណៈពេលដែលអ្នកខ្លះទៀតជ្រើសរើសយកនូវវិធីហឹង្សានិងការប្រព្រឹត្តនូវបទល្មើសដើម្បីយកមកធ្វើការដោះស្រាយ ។

ទាំងនេះវាក៏អាស្រ័យទៅតាមចរិកលក្ខណៈរបស់មនុស្សម្នាក់ៗដែរ កត្តាគ្រួសារ កត្តាសង្គម និងការអប់រំចូលរួមផងដែរដែលជំរុញឲ្យមានបទល្មើសកើតឡើង ។ ដើម្បីបំពេញនូវតម្រូវការនិងភាពខ្វះខាតដែលខ្លួនពុំអាចនឹងមានលទ្ធភាពបំពេញបានដោយសមត្ថភាពផ្ទាល់ បង្ខំឲ្យមនុស្សម្នាក់ប្រព្រឹត្តនូវអំពើល្មើសដើម្បីទទួលបាននូវផលប្រយោជន៍ ។ តើអំពើអ្វីខ្លះទៅដែលច្បាប់ចាត់ទុកថាជាបទល្មើស? ដោយហេតុថាមនុស្សម្នាក់ៗកើតមកហើយត្រូវទទួលបាននូវសិទ្ធិផ្ទាល់ខ្លួនដោយពុំអាចមាននរណាម្នាក់មកបំពារបំពានបានទាំងផ្លូវកាយនិងផ្លូវចិត្តផងនោះ ហេតុនេះហើយទើបបានជាច្បាប់ការពារនូវរាល់ការរំលោភបំពានទាំងឡាយរវាងគ្នានិងគ្នា ហើយកំនត់ទុកជាមុននូវបទល្មើសទាំងឡាយដែលអាចកើតមានឡើងនៅក្នុងច្បាប់ជាមុន ។ បទល្មើសគឺជាអំពើដែលកើតចេញពីឆន្ទៈរបស់បុគ្គលម្នាក់ដែលបង្កគ្រោះថ្នាក់បំពានទៅនឹងច្បាប់ព្រហ្មទណ្ឌ ដែលកម្មវត្ថុនៃបទល្មើសមានចែងកំណត់ក្នុងច្បាប់រួចហើយ ។ រាល់បទល្មើសទាំងឡាយណាដែលពុំមានចែងក្នុងច្បាប់គឺពុំអាចចាត់ទុកជាបទល្មើសទេ ។

ការបកស្រាយនូវខ្លឹមយ៉ាងខ្លីខាងលើ មិនអាចឱ្យអ្នកដឹងច្បាស់ពីទំនាក់ទំនងនៃបទល្មើសនោះទេ ដើម្បីអាចចាត់ទុកអំពើមួយជាបទល្មើសបានយើងត្រូវស្គាល់ពីសញ្ញាណនៃបទល្មើស (ផ្នែកទី១ ) និងចរិកលក្ខណៈរបស់បទល្មើស(ផ្នែកទី២) ផងដែរ ។

# ផ្នែកទី១៖ សញ្ញាណនៃបទល្មើស

ការសិក្សាសញ្ញាណនៃបទល្មើសគឺជាចំណុចចាប់ផ្តើមមួយ ដែលធ្វើឲ្យយើងដឹងថាសកម្មភាពមួយឬអំពើមួយត្រូវបានច្បាប់កំណត់ថាជាបទល្មើសហើយសកម្មភាព ឬអំពើដែលច្បាប់បានកំណត់ថាជាបទល្មើសនោះបង្កើតឲ្យមានជាព្យសនកម្មចំពោះសង្គមនិងប្រទេសជាតិ ។ ចំពោះអ្នកប្រព្រឹត្តបទល្មើសគឺត្រូវតែទទួលរងនូវទណ្ឌកម្មដែលជាការកំណត់របស់ច្បាប់។

**១. អំពើ**

នៅក្នុងការសិក្សាបែបឧក្រិដ្ឋវិទ្យា អំពើគឺជាសិក្សាពីស្ថានភាពដែលនាំឱ្យមានបទល្មើសហើយក៏ជាការសិក្សាអំពីអំពើដែលច្បាប់សន្មតថាជាបទល្មើសផងដែរ។ ប្រសិនបើច្បាប់មិនបានចែងថាអំពើណាមួយនោះគឺជាបទល្មើសទេ ការប្រព្រឹត្តរបស់បុគ្គលនោះត្រូវចាត់ទុកថាមិនមែនជាបទល្មើស។ បើសិក្សាឱ្យស៊ីជំរៅទៅចំពោះអំពើនេះគឺបង្ហាញឱ្យឃើញពីមូលហេតុដែលនាំឱ្យមានអំពើល្មើសកើតមានឡើង។

អំពើរបស់មនុស្សគឺបញ្ជាក់អំពីឆន្ទៈនិងទិសដៅហើយជាបាតុភូតស្មុគស្មាញ និងសំបូរបែបមុនឈានទៅដល់ការប្រព្រឹត្តនៅអំពើល្មើស ហើយក៏ជាសញ្ញាណសំគាល់យ៉ាងសំខាន់មួយនៃធាតុសម្ភារៈឬធាតុសត្យានុម័តពីព្រោះនេះជាមូលហេតុដែលនាំមកនូវអំពើល្មើស ដែលបង្កជាគ្រោះថ្នាក់ដល់សង្គមនិងប្រទេសជាតិ។

**១.១. ធាតុសត្យានុម័តឬធាតុសម្ភារៈ**

នៅក្នុងនីតិព្រហ្មទណ្ឌធាតុសត្យានុម័តជាធាតុមួយដែលសំខាន់ ក្នុងការកំណត់ថាតើអំពើណាមួយជាបទល្មើស។ ធាតុសត្យានុម័តជាអំពើល្មើសទាំងឡាយដែលបុគ្គលម្នាក់បានប្រព្រឹត្តក្រោមរូបភាពជាអំពើសកម្មក្តីឬអកម្មក្តីដែលមានចរិកលក្ខណៈបង្កគ្រោះថ្នាក់ដល់សង្គម ។ ដើម្បីអនុវត្តនូវអំពើរបស់ខ្លួនឲ្យបានសម្រេច ជនល្មើសប្រាកដជានឹងប្រើប្រាស់នូវគ្រប់មធ្យោបាយដែលក្នុងនោះជនល្មើសចាំបាច់ត្រូវប្រើឧបករណ៍ ឬកលល្បិចសព្វបែបយ៉ាងដើម្បីប្រព្រឹត្តអំពើល្មើសមួយក្នុងស្ថានភាពនិងពេលវេលាមួយជាកំណត់។

នៅក្នុងន័យឧក្រិដ្ឋវិទ្យា អំពើដែលជាកត្តាសត្យានុម័តចែកចេញជា២ប្រភេទគឺ៖ ភាពមិនចុះសម្រុងនៅក្នុងសង្គម និងការប្រែប្រួល។

**១.១.១.ភាពមិនចុះសម្រុង**

បុព្វហេតុនៃភាពមិនចុះសម្រុងហើយនឹងបង្កឲ្យទៅជាបទល្មើស គឺអាស្រ័យទៅនឹងANOMIA ។ តម្រូវការនៃភាពចាំបាច់នេះមានសំពាធទៅលើអារម្មណ៍របស់បុគ្គលហើយទាម

ទារឲ្យបញ្ចេញនូវសកម្មភាពមួយឡើង។

ANOMIA៖ សំដៅទៅលើអំពើដែលប្រព្រឹត្តល្មើសដើម្បីបំពេញនូវតម្រូវការរបស់ខ្លួន។ឧទាហរណ៍បុគ្គលម្នាក់គាត់ត្រូវការលុយជាចាំបាច់ដើម្បីព្យាបាលជម្ងឺ ប៉ុន្តែគាត់គ្មានលទ្ធភាពទាល់តែសោះក្នុងការរកលុយគាត់ក៏បង្វែរគោលដៅទៅប្រព្រឹត្តបទល្មើស ដើម្បីយកលុយទៅបង់សេវាកម្មផ្នែក សុខាភិបាល។

**១.១.២.ការប្រែប្រួល**

សំដៅទៅលើរបត់នៃសង្គមដែលរួមមានផ្នែកសេដ្ឋកិច្ច និងការវិវត្តនៃសង្គមមនុស្សដែលធ្វើឲ្យចរិករបស់មនុស្សមានការប្រែប្រួល។

**១.២. ធាតុអត្តនោម័ត**

ធាតុអត្តនោម័តជាទិដ្ឋភាពខាងក្នុងនៃជនល្មើស ដូចជាកំហុសគោលបំណងនិងកត្តាជំរុញនាំឲ្យមានការប្រព្រឹត្តបទល្មើស។ ធាតុអត្តោម័តគឺជាចេតនាប្រព្រឹត្តបទល្មើសជាឆន្ទៈឆ្ពោះទៅកាន់ការសម្រេចបទល្មើសមានន័យថាពេលប្រព្រឹត្តបទល្មើសអំពើបង្កគ្រោះថ្នាក់ដល់សង្គម ជនល្មើសយល់ដឹងច្បាស់នូវកម្រិតគ្រោះថ្នាក់ដល់សង្គមនូវអំពើរបស់ខ្លួន ដឹងជាមុននូវផលវិបាកនឹងកើតឡើងដោយសារអំពើប្រព្រឹត្តរបស់ខ្លួន ដែលបានបង្កឡើងហើយនៅតែចង់ឲ្យផលវិបាកនោះកើតមានឡើង។

**២. ព្យសនកម្ម**

អំពើទាំងឡាយណាដែលច្បាប់បានកំណត់ថាជាបទល្មើស ទាល់តែអំពើនោះបានបង្កឲ្យមាននូវព្យសនកម្មដល់សង្គមនិងប្រទេសជាតិ ។ នៅក្នុងន័យឧក្រិដ្ឋវិទ្យាគេសិក្សាតាមVictimology ដែលជាវិទ្យាសាស្ត្រសិក្សាអំពីភាពរងគ្រោះដោយសារបទល្មើស។ ភាពរងគ្រោះដោយសារបទល្មើសមានបីប្រភេទគឺ៖ ភាពរងគ្រោះផ្នែកសម្ភារៈ ភាពរងគ្រោះផ្នែករូបរាងកាយនិងជីវិត និងភាពរងគ្រោះផ្នែកស្មារតី។

**២.១. ភាពរងគ្រោះផ្នែកសម្ភារៈ**

ភាពរងគ្រោះផ្នែកសម្ភារៈនេះអាចដោះដូរជាទឹកប្រាក់បាន ឬធ្វើឲ្យដូចដើមនៅក្នុងលក្ខខណ្ឌនៃច្បាប់ ។

**២.២. ភាពរងគ្រោះផ្នែករូបរាងកាយនិងជីវិត**

ភាពរងគ្រោះផ្នែករូបរាងកាយនិងជីវិត មានន័យថាជាលទ្ធផលដែលបន្សល់ទុកបន្ទាប់ពីបទល្មើសមួយបានកើតឡើង។ នៅពេលដែលជនល្មើសបានប្រព្រឹត្តនូវអំពើល្មើសមួយប្រាកដណាស់ថាជនល្មើសពិតជាមានគោលបំណងចង់បាននូវអ្វីមួយពីជនរងគ្រោះ ។ ដើម្បីបាន

នូវវត្ថុដែលខ្លួនចង់បានជនល្មើសត្រូវតែប្រើប្រាស់នូវឧបករណ៍ ឬដោយវិធីសាស្ត្រណាមួយទៅលើជនរងគ្រោះហេតុនេះព្យសនកម្មប្រាកដជាកើតមានចំពោះជនរងគ្រោះ អាចទៅលើរូបរាងកាយបង្កឲ្យមានរបួសស្នាមឬផ្តាច់ដល់ជីវិតក៏មាន។

តាមទ្រឹស្តីឧក្រិដ្ឋវិទ្យាការរងគ្រោះដល់រូបរាងកាយ និងជីវិតបែងចែកចេញជាពីរផ្នែក ដោយផ្អែកលើគោលបំណងនិងមូលហេតុនៃបទល្មើស។

**ក.ផ្នែករូបរាងកាយ៖** ករណីខ្លះការរងគ្រោះអាចមានរូបរាងកាយផងនិងជីវិតផងនិងករណីផ្សេងទៀតការរងគ្រោះនេះដាច់ដោយឡែកពីគ្នា។ ចំពោះការរងគ្រោះដល់រូបរាងកាយច្រើនតែកើតឡើងទៅលើអំពើទាំងឡាយណាដូចជាអំពើដែលមានគោលបំណងបំផ្លិចបំផ្លាញ ឬខូចខាតផ្នែករូបរាងកាយហើយមានច្រើនប្រភេទដូចជា អំពើភេរវកម្មឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសសាមញ្ញមួយចំនួនទៀត ។

**ខ.ជីវិត៖** នៅពេលដែលអំពើល្មើសប៉ះផ្តាច់ជីវិតបុគ្គលនៅក្នុងទ្រឹស្តីឧក្រិដ្ឋវិទ្យាចាត់ទុកថាជាការបំផ្លាញមួយទាក់ទងទៅនឹងការបិទសិទ្ធិសេរីភាព(យកជីវិតដោយខុសច្បាប់) ។

### ២.៣. ភាពរងគ្រោះផ្នែកស្មារតី

ភាពរងគ្រោះផ្នែកស្មារតី ជាការប៉ះពាល់ដល់សតិអារម្មណ៍ដែលទស្សនៈនៃការផ្តន្ទាទោសនេះត្រូវបានគេកំណត់និងវិភាគទៅតាមទស្សនៈPositive (ដែលជាការវិភាគតាមបែបវិទ្យាសាស្ត្រ)។

## ៣. ទណ្ឌកម្ម

ទណ្ឌកម្ម គឺជាការដាក់ទោសទៅលើបុគ្គលដែលប្រព្រឹត្តនូវបទល្មើសណាមួយដែលបង្កគ្រោះថ្នាក់ដល់សង្គម ឬ ប្រទេសជាតិ ។ ពុំមានទណ្ឌកម្មណាមួយអាចធ្វើទៅលើជនណាម្នាក់ឡើយប្រសិនបើជននោះមិនបានប្រព្រឹត្តអំពើដែលច្បាប់កំណត់ថាមិនមែនជាបទល្មើស។

ទណ្ឌកម្ម ត្រូវកំណត់ទៅតាមប្រភេទនៃបទល្មើសដូចជាបទល្មើសលហុ បទល្មើសមជ្ឈិមនិងប្រភេទបទល្មើសឧក្រិដ្ឋ។ ការដាក់នូវទណ្ឌកម្ម គឺជាវិធីសាស្ត្រមួយដែលធ្វើឡើងដើម្បីធ្វើឱ្យអ្នកប្រព្រឹត្តអំពើខុសច្បាប់ រាងចាលលែងហ៊ានប្រព្រឹត្តកំហុសតទៅទៀត ។ ទណ្ឌកម្មមិនមែនជាការធ្វើបាបទៅលើបុគ្គលដែលប្រព្រឹត្តបទល្មើសនោះទេ ប៉ុន្តែវាជាវិធានមួយដែលធ្វើឱ្យការប្រព្រឹត្តបទល្មើសមានការធ្លាក់ចុះ និងកាត់បន្ថយ ហើយវាប្រែប្រួលទៅតាមស្ថានភាពសង្គម។ ទណ្ឌកម្មត្រូវបានបែងចែកជាពីរប្រភេទ គឺទណ្ឌកម្មដែលផ្តន្ទាទោសចំពោះការប្រព្រឹត្តល្មើស និងទណ្ឌកម្មជាការដាក់ពិន័យចំពោះការប្រព្រឹត្តល្មើស។

**៣.១. ទណ្ឌកម្មជាការផ្តន្ទាទោស**

ការផ្តន្ទាទោស ជាវិធីមួយដែលកើតឡើងបន្ទាប់ពីការចោទប្រកាន់ពីបទល្មើស ហើយការដាក់ទណ្ឌកម្មទាំងអស់មិនមែនមានគោលបំណងសងសឹងនោះទេ នេះគឺជាមធ្យោបាយបែបឧក្រិដ្ឋវិទ្យាដែលសិក្សាពីចិត្តរបស់មនុស្សមុននឹងបញ្ញត្តិនូវច្បាប់ឡើង ហើយកំណត់ថាអំពើនោះគឺជាបទល្មើស ។ ការដាក់ទណ្ឌកម្មប្រភេទនេះ គឺជាគំនិតមួយដែលធ្វើឱ្យមនុស្សខ្លាចដោយសារការឃុំឃាំង ហើយក៏ជាគោលការណ៍មួយដែរដែលធ្វើឡើងដើម្បីរក្សានូវស្ថានភាពសង្គម និងប្រទេសកុំឲ្យមានភាពរីករវដោយសារតែបុគ្គលប្រព្រឹត្តបទល្មើស។

ទណ្ឌកម្ម ជាទោសជាកាតព្វកិច្ចដើម្បីឆ្លើយតបទៅនឹងអំពើប្រព្រឹត្តបទល្មើសទាំងឡាយនៅក្នុងលក្ខខណ្ឌមួយចំនួន និងយោងទៅតាមបទបញ្ញត្តិច្បាប់ មានន័យថាជាការទទួលរងនូវទណ្ឌកម្មដោយសារការប្រព្រឹត្តបទល្មើសរបស់ជនល្មើស ដែលបណ្តាលឲ្យមានការប៉ះពាល់ដល់អាយុជីវិត សេចក្តីថ្លៃថ្នូរ សុខភាព និងទ្រព្យសម្បត្តិអ្នកដទៃដែលច្បាប់បានការពារ ។

**៣.២. ទណ្ឌកម្មជាការផាកពិន័យ**

ទណ្ឌកម្មប្រភេទនេះ គឺជាទណ្ឌកម្មដែលត្រូវបង្កើតឡើងដោយជនរងគ្រោះ ដែលបានដាក់ពាក្យបណ្តឹងស្នើសុំទាមទារការសងជាសំណងរដ្ឋប្បវេណី ដែលកើតឡើងពីព្យសនកម្មនៃអំពើល្មើស ។ នេះគឺជាទទួលខុសត្រូវរបស់ជនល្មើសដែលប្រព្រឹត្តអំពើល្មើស ហើយបង្កឱ្យមានព្យសនកម្មទៅលើអ្នកដទៃ។

**៤. ច្បាប់**

នៅក្នុងការសិក្សាពីមុខវិជ្ជាឧក្រិដ្ឋវិជ្ជា ច្បាប់គឺជាសញ្ញាណមួយកំនត់អំពីធាតុផ្សំនៃបទល្មើសទៅលើអំពើណាមួយបានកើតឡើង ហើយថាតើអំពើនោះត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌដែលបានកំនត់ទុកនៅក្នុងក្រមព្រហ្មទណ្ឌដែរឬទេ? បញ្ហាច្បាប់ គឺបញ្ហាសំខាន់ដែលត្រូវសិក្សាពីបំរែបំរួលនៃអំពើល្មើស ហើយត្រូវបញ្ញត្តនូវច្បាប់បន្ថែម ឬ វិសោធន៍កម្មនូវច្បាប់ទាំងនោះដើម្បីអាចដាក់ទោសនូវអំពើល្មើសដែលបង្កឱ្យមានព្យសនកម្ម។ ប្រសិនបើការវិវត្តរបស់អំពើល្មើសចេះតែកើតឡើងថ្មីៗ ហើយច្បាប់មិនមានការវិវត្តន៍វិញនោះគឺជាបញ្ហាដែលមិនអាចគ្រប់គ្រងបាននូវបទល្មើស ហើយអំពើល្មើសចេះតែកើតមានឡើងជាបន្តបន្ទាប់រហូត ។

ការសិក្សាពីបញ្ហាច្បាប់ គឺជាការសិក្សាពីអំពើល្មើស ហើយត្រូវបញ្ញត្តច្បាប់បែបណាទើបអាចដាក់ទណ្ឌកម្មទៅលើជនល្មើសបាន។

# ផ្នែកទី២ ៖ ចរិកលក្ខណៈនៃបទល្មើស

ចរិកលក្ខណៈនៃបទល្មើស ជាការសិក្សាពីគោលបំណង ឬមូលហេតុ ឬបុព្វហេតុ ដែលនាំឱ្យបុគ្គលម្នាក់ប្រព្រឹត្តអំពើល្មើសដែលច្បាប់កំណត់ថាជាបទល្មើស។អំពើល្មើសទាំងនោះ អាចត្រូវបានកើតមានឡើងដោយសារទំនាក់ទំនងហេតុនិងផល ដែលជំរុញឱ្យមនុស្សម្នាក់ប្រព្រឹត្តបទល្មើសដែលបង្កឱ្យមានព្យសនកម្ម ដល់សង្គម និងប្រទេសជាតិ ។ ទំនាក់ទំនងនេះ គឺត្រូវសិក្សាអំពីកត្តាខាងក្រៅ និងកត្តាខាងក្នុងដែលរួមផ្សំគ្នាបង្កើតឱ្យបុគ្គលមួយមានឆន្ទៈ គំនិតល្អ ក្លាយទៅជាមានគំនិតអាក្រក់ដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្លួន។ ប្រសិនបើគ្មានឥទ្ធិពលនៃទំនាក់ទំនងពីកត្តាខាងក្រៅរួមជាមួយកត្តាខាងក្នុងនោះទេ បុគ្គលម្នាក់ក៏មិនអាចឈានទៅដល់ការប្រព្រឹត្តបទល្មើសនោះដែរ ។

នៅក្នុងការសិក្សាបែបឧក្រិដ្ឋវិទ្យា ការវិភាគលើបទល្មើសគឺវិភាគក្នុងលក្ខណៈពីរគឺ៖ បុគ្គលិកលក្ខណៈបុគ្គល និងការវិវត្តន៍របស់សង្គម ។

**១. បុគ្គលិកលក្ខណៈរបស់បុគ្គល (កត្តាខាងក្នុង)**

កត្តាខាងក្នុង ឬបុគ្គលិកលក្ខណៈរបស់ជនល្មើសឬបុគ្គលម្នាក់ គឺជាការសិក្សាពីលក្ខណៈសំគាល់ផ្នែកសីលធម៌ និងចិត្តសាស្ត្រទៅលើបុគ្គល ឬក៏អាចនិយាយបានថា គឺជាការសិក្សាទៅលើចិត្តនិងអត្តចរិកដែលមានមកពីធម្មជាតិរបស់បុគ្គល ។ ផ្នែកខាងក្នុងនៃបុគ្គលិកលក្ខណៈបុគ្គលត្រូវបានស្តែងឡើងតាមរយៈបណ្តាសញ្ញាផ្សេងៗដែលទាក់ទងនឹងស្មារតី មនសិការ ហើយដែលលក្ខណៈសំគាល់នេះ ធ្វើឱ្យចោទជាសំនួរថា តើហេតុអ្វីបានជាជននេះប្រព្រឹត្តបទល្មើស?

លក្ខណៈសំគាល់នេះត្រូវបានលេចចេញតាមរយៈទស្សនៈ ការយល់ដឹងអាកប្បកិរិយារបស់បុគ្គលចំពោះតម្លៃសង្គមរបស់បុគ្គលនោះ ដូចជាចំពោះកាតព្វកិច្ចរបស់ពលរដ្ឋចំពោះមាតុភូមិ ពលកម្ម ច្បាប់ ចំពោះគ្រួសារ ចំពោះបុគ្គលផ្សេងទៀតជុំវិញខ្លួន និងចំពោះខ្លួនឯង ។ នៅពេលដែលបុគ្គលនោះកំណត់អំពីទិសដៅណាមួយចំពោះតម្លៃសង្គមណាមួយ នោះអាចវាយតម្លៃបាននូវទិសដៅនៃការរីកចំរើនរបស់ជននោះ។ទំហំនៃការវិវត្តន៍របស់បុគ្គលបានដៅទិសត្រឹមត្រូវមានប្រយោជន៍សំរាប់សង្គម ឬបង្កឱ្យមានអន្តរាយដល់សង្គម ។

លក្ខណៈសំគាល់នៃសីលធម៌ ចិត្តសាស្ត្រសង្គមត្រូវការ ចំណង់ចំណូលចិត្ត ចំពោះប្រភេទនៃសកម្មភាពរបស់មុនស្ស ។ សេចក្តីត្រូវការ ចំណូលចិត្តរបស់ជនល្មើស ដែលប្រព្រឹត្តដោយមូលហេតុផលប្រយោជន៍សេដ្ឋកិច្ច មានភាពខុសគ្នាជាមួយនឹងសេចក្តីត្រូវការ និងចំណូលចិត្តរបស់ជន

ល្មើសប្រព្រឹត្តបំពានលើរូបកាយ សុខភាព កិត្តិយស និងអាយុជីវិតរបស់មនុស្ស ។

លក្ខណៈជីវៈចិត្តសាស្ត្រ នៃសកម្មភាពជនល្មើសដែលក្តោបយកនូវចរិកលក្ខណៈតពូជ និងពីកំណើតរបស់បុគ្គល ព្រមទាំងរាល់ការប្រែប្រួលក្រោយឥទ្ធិពលចិត្តសាស្ត្រ ដែលនាំឱ្យបុគ្គលម្នាក់ប្រព្រឹត្តបទល្មើសគឺជាកត្តាខាងក្នុងរបស់មនុស្ស ។

**១.១. ឥទ្ធិពលនៃសរីរៈតពូជ ឬការសិក្សាពីតំណពូជ**

ឥទ្ធិពលនៃសរីរៈតពូជ គឺជាការសិក្សាពីសញ្ញាមួយចំនួនបានមកពីការបញ្ជូនពូជតាមរយៈហ្សែន។ បញ្ហាហ្សែន ដែលជាធាតុរបស់ក្រូម៉ូសូម ជាការសិក្សាពីការបង្កើតឡើងវិញនូវខ្សែស្រឡាយគ្រួសារ ពីឪពុកម្តាយទៅកូន ពីមួយជំនាន់ទៅមួយជំនាន់។

ក្នុងការសិក្សា ដើម្បីអាចដឹងថាតើពិតជាមានការចម្លងហ្សែនមែន ឬអត់? គេបានសិក្សាលើវិធីបីយ៉ាងក្នុងរូមមានៈ

**វិធីសាស្ត្រទី១ៈ** ការរកខ្សែញាតិរបស់គ្រួសារមួយ ហើយគណនាថាមានករណីល្មើសប៉ុន្មានដង ដែលកើតមានឡើងក្នុងគ្រួសារនោះ?ហើយថាតើបទល្មើសណាខ្លះ ដែលបានប្រព្រឹត្តពីជំនាន់មួយទៅជំនាន់មួយទៀត?

**វិធីសាស្ត្រទី២ ៈ**ការសង្កេតទៅលើជនល្មើសមួយក្រុម ដោយស្វែងរកចំពោះជនម្នាក់ៗ ថាតើមានបច្ឆាញាតិប៉ុន្មាននាក់ដែលជាជនល្មើស?

**វិធីសាស្ត្រទី៣ ៈ**ការប្រៀបធៀបអត្តចរិករបស់កូនភ្លោះ ដែលកើតមានឡើងដោយការបែងចែករបស់ក្រូម៉ូសូមតែមួយ និងអត្តចរិករបស់កូនភ្លោះដែលកើតមានឡើងដោយក្រូម៉ូសូមខុសគ្នា។ ការប្រៀបធៀបនេះ ឲ្យលទ្ធផលថាកូនភ្លោះ ប្រភេទទីមួយមានហ្សែនដូចគ្នា ដូច្នេះបើកូនភ្លោះម្នាក់មានហ្សែនដែលមានទំនាក់ទំនងទៅរកការធ្វើឧក្រិដ្ឋកម្ម កូនភ្លោះមួយទៀតដ៏ដូចគ្នានេះដែរ ។

គេសង្កេតឃើញថា មានភាពស៊ីចង្វាក់គ្នារវាងអត្តចរិករបស់កូនភ្លោះប្រភេទទីមួយនេះ មានរហូតដល់ទៅ ២ ទៅ ៣ លើក។ ចំណែកឯកូនភ្លោះប្រភេទទីពីរ ភាពស៊ីសង្វាក់គ្នានេះ មានតែមួយលើ ៣ តែប៉ុណ្ណោះ។ តាមការរកឃើញរបៀបនេះ គេអាចធ្វើការសន្និដ្ឋានបានថាមានឥទ្ធិពលតែការចម្លងផ្នែកតំណពូជតែប៉ុណ្ណោះ។

គួរគូសបញ្ជាក់ឱ្យច្បាស់ដែរថា គេមិនអាចរកឃើញក្រូម៉ូសូមឧក្រិដ្ឋមួយនោះទេ បានន័យថាអ្វីដែលចម្លងពីមេទៅកូននោះ មិនមែនជាក្រូម៉ូសូមទេ តែជាទំនោររបស់មេបានោះ ដែលជាមូលដ្ឋានក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដូចជាៈ ភាពឃោរឃៅ ភាពដែលឆាប់ទាក់ទាញអារម្មណ៍ ។ល។

**១.២. ឥទ្ធិពលនៃស្ថានភាពខាងក្នុងរាងកាយបុគ្គល**

ឥទ្ធិពលនៃផ្នែកខាងក្នុងរាងកាយរបស់បុគ្គល គឺជាការសិក្សាពីសរីរាង្គខាងក្នុងរបស់

បុគ្គលអាចបណ្តាលមកពីប្រវត្តិរបស់ជននោះពីកំណើត ឬក្រោយពេលកើត ដែលចូលរួមក្នុងការបង្កើតនូវបុគ្គលភាពរបស់ជនល្មើស។

**-ប្រវត្តិមុនពេលកើត៖** គឺជាការលូតលាស់មិនប្រក្រតីរបស់មនុស្ស ដែលបណ្តាលឲ្យមានបញ្ហាខាងផ្នែកស្មារតី ឬអកប្បកិរិយា និងបង្កើតក្រូម៉ូសូមខុសប្លែកពីគេ។

**-ប្រវត្តិនៅពេលកើត៖** គឺជាការសិក្សាពីភាពរអាក់រអួលនៅពេលសំរាលកូន ដែលជាហេតុផលមួយអាចនាំឲ្យមានបញ្ហាខាងប្រព័ន្ធសរសៃប្រសាទរបស់កូននោះ។

**-ប្រវត្តិក្រោយពេលកើត៖** គឺជាការសិក្សាពីការឆ្លងជម្ងឺ ដែលបណ្តាលឲ្យរំខានដល់ប្រព័ន្ធខួរក្បាល ការប្រែប្រួលដែលបណ្តាលមកពីការសេពសុរា ឬស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ច្រើនពេក ជាពិសេសនៅពេលពេញវ័យ។ ជម្ងឺអាចបង្កឱ្យមានភាពពិការ ឬកាត់បន្ថយសមត្ថភាពធ្វើការ នាំឲ្យក្លាយជាជនឥតមានការងារធ្វើ។ ការរកឃើញថ្មីនេះ បង្ហាញឲ្យឃើញភាពមើលមិនឃើញរបស់ក្មេងដែលមិនទាន់ព្យាបាល អាចធ្វើឱ្យក្មេងមិនយកចិត្តទុកដាក់ក្នុងការសិក្សា ហើយងាយនឹងធ្លាក់ក្នុងអំពើល្មើសណាមួយ។

កត្តាខាងលើ មិនមែនជាកត្តាដែលជំរុញឱ្យមានអំពើល្មើសដោយផ្ទាល់នោះទេ តែវាជាកត្តា ដែលចូលរួមក្នុងការកាត់បន្ថយនូវតុល្យភាពចិត្តសាស្ត្រ និងធ្វើឱ្យជននោះងាយនឹងទទួលរងឥទ្ធិពលពីកត្តាខាងក្រៅទៀតផងធ្វើឱ្យកើតមាននូវបទល្មើស។

**២. ការវិវត្តន៍របស់សង្គម (កត្តាខាងក្រៅ)**

ក្រៅអំពីកត្តាខាងក្នុងដែលអាចនាំឲ្យបុគ្គលម្នាក់ប្រព្រឹត្តនូវបទល្មើស កត្តានៃការវិវត្តន៍របស់សង្គមក៏បានរួមចំណែកយ៉ាងធំដែលឲ្យបុគ្គលម្នាក់ប្រព្រឹត្តនូវបទល្មើសបានដែរ ។ នៅពេលដែលសង្គមកាន់តែមានការវិវត្តន៍ ឥទ្ធិពលនៃផលប៉ះពាល់និងការហូរចូលនូវវប្បធម៌បរទេសនានាក៏មានកាន់តែច្រើន សម្ភារៈ បច្ចេកវិជ្ជា និង វិទ្យាសាស្ត្រទំនើបៗក៏ជាកត្តាដែលនាំឲ្យបទល្មើសកើតមានកាន់តែច្រើននិងមានលក្ខណៈប្លែកៗផងដែរ ។

ចរិកលក្ខណៈនៃបទល្មើសបែបឧក្រិដ្ឋវិទ្យាជាការសិក្សាពីស្ថានភាព និងប្រភពដែលនាំឱ្យមានបទល្មើសកើតឡើង និងវិភាគអំពីបាតុភូត ។ ឧក្រិដ្ឋវិទ្យាចាត់ទុកបទល្មើសត្រូវតែមាននៅក្នុងសង្គមដោយសារកត្តាមួយចំនួនដែលជាការវិវត្តន៍របស់សង្គម ។

**២.១. កត្តាសង្គម**

ឧក្រិដ្ឋវិទ្យាបានឲ្យនិយមន័យទៅលើមជ្ឍដ្ឋានសង្គមថាជាស្ថានភាពសង្គម សកម្មភាពសង្គម ទំនាក់ទំនងសង្គម ដែលហ៊ុំព័ទ្ធជុំវិញបុគ្គលហើយមានឥទ្ធិពលទៅលើសតិសម្បជញ្ញៈ និង ឥរិយាបទបុគ្គល ។

កត្តាសង្គមជាកត្តាបរិយាកាសដ៏សំខាន់មួយ ដែលជះឥទ្ធិពលដល់ការកកើតឡើងនៃអំពើល្មើស ។ កត្តាសង្គមនៅក្នុងន័យនេះសំដៅទៅលើសង្គមគ្រួសារដែលជាកកត្តាផ្ទាល់រហូតដល់សង្គមខាងក្រៅ នៅពេលដែលពួកគេចាប់ផ្តើមប្រាស្រ័យទាក់ទងនឹងមជ្ឈដ្ឋានជុំវិញខ្លួនក្រៅអំពីក្រុមគ្រួសារពោលគឺពេលដែលពួកគេចាប់ផ្តើមចូលសាលារៀន។

សង្គមគ្រួសារជាសង្គមមួយដែលផ្តល់ការអភិវឌ្ឍន៍ ភាពស្រលាញ់ ការថ្នាក់ថ្នមដល់ក្មេងតាំងពីពេលចាប់កំណើតរហូតដល់ធំពេញវ័យ ។ ទង្វើល្អនិងទង្វើអាក្រក់ស្ថិតនៅលាយឡំគ្នាក្នុងសង្គមគ្រួសារមួយ ហើយកុមារនឹងអាចស្រូបទាញឬទទួលយកនូវឥទ្ធិពលទាំងនេះដោយងាយស្រួល ដោយហេតុថាធម្មជាតិរបស់កុមារគឺអភិវឌ្ឍដោយការត្រាប់តាមពីមនុស្សដែលនៅជុំវិញខ្លួនរបស់វា ។ ម្យ៉ាងវិញទៀតកុមារជាវ័យដែលងាយនឹងទទួលរងនូវឥទ្ធិពលពីខាងក្រៅបានយ៉ាងឆាប់រហ័សព្រោះតែកុមារមិនអាចនឹងបែងចែកបានរវាងអំពើណាមួយជាអំពើល្អ និងអំពើណាជាអំពើអាក្រក់ ហេតុនេះហើយសកម្មភាពអាក្រក់បស់មនុស្សចាស់ និងមធ្យោបាយដែលមនុស្សចាស់បង្រៀនក្មេងវានឹងជះឥទ្ធិពដល់ក្មេងនាពេលអនាគត។

ឧ. នៅក្នុងគ្រួសារមួយនៅពេលដែលឪពុកម្តាយមានការឈ្លោះប្រកែកគ្នា គាត់តែងប្រើអំពើហិង្សានិងសម្តែងចេញឲ្យកូនតូចៗរបស់គាត់បានឃើញពីសកម្មភាពរបស់ពួកគាត់ ។ ក្មេងនៅពេលដែលវាបានឃើញនូវសកម្មភាពអស់ទាំងនេះ គេនឹងធ្វើត្រាប់តាមដោយមិនដឹងថានេះជាសកម្មភាពនេះល្អឬអាក្រក់ឡើយ ។

ក្រៅអំពីសង្គមគ្រួសារ នៅពេលកុមារឈានដល់វ័យចូលសាលារៀនពួកគេចាប់ផ្តើមមានទំនាក់ទំនងជាមួយសង្គមខាងក្រៅនិងមនុស្សមួយចំនួនដែលនៅក្បែរខាង ។ មជ្ឈដ្ឋានសាលារៀន អាចអនុញ្ញាតឲ្យកុមារជួបប្រាស្រ័យទាក់ទងនឹងសង្គមអាក្រក់បានដោយងាយ ព្រោះសាលារៀនជាទីប្រជុំនូវមនុស្ស ដែលមកពីគ្រប់មជ្ឈដ្ឋានទាំងអស់ក្នុងសង្គម មានទាំងល្អនិងអាក្រក់ ។ ប្រសិនបើកុមារងាយនឹងត្រូវបានគេអូសទាញនោះ គេនឹងធ្លាក់ចូលទៅក្នុងសង្គមអាក្រក់បានដោយស្វ័យប្រវត្តិ ដូចជាត្រូវបានមិត្តភក្តិនាំឲ្យ ទៅលួច ឆក់ និង ប្រើប្រាស់នូវគ្រឿងញៀនជាដើម ។

**២.២. កត្តានៃស្ថានភាពសេដ្ឋកិច្ច**

ប្រព័ន្ធសេដ្ឋកិច្ចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទំនាក់ទំនងនានាក្នុងសង្គម ដូចជានយោបាយ នីតិ សីលធម៌ ការអប់រំ ជាដើម។ ទំនាក់ទំនងសេដ្ឋកិច្ច គឺជាបាតុភូតសង្គមដែលតែងតែវិវឌ្ឍន៍ និង ផ្លាស់ប្តូរតាមដំណាក់កាលប្រវត្តិសាស្ត្ររបស់សង្គមមនុស្ស ។ ការផ្លាស់ប្តូរនូវរបបសេដ្ឋកិច្ចពីរបបមួយទៅរបបមួយធ្វើឲ្យទំនាក់ទំនងសង្គមផ្សេងទៀតមានការប្រែប្រួល។ ការវិវត្តន៍ពីសេដ្ឋ

កិច្ចផែនការមកសេដ្ឋកិច្ចទីផ្សារសេរីជាសត្យានុម័តនាំមកនូវទំនាស់រវាងសេដ្ឋកិច្ចនិងសង្គម ដោយហេតុថា គោលដៅនៃសេដ្ឋកិច្ចទីផ្សារសេរី គឺជាការស្វែងរកប្រយោជន៍ផ្នែកសេដ្ឋកិច្ចហើយដែលនៅក្នុងនោះ វាពុំបានធានានូវបញ្ហាសង្គមទូទៅឡើយ។

នៅពេលដែលយើងនិយាយដល់សេដ្ឋកិច្ចទីផ្សារសេរី ត្រូវនិយាយដល់កម្មសិទ្ធិជាច្រើនសមាសភាពចំពោះមធ្យោបាយពាណិជ្ជកម្ម បច្ចេកវិជ្ជាទំនើបៗ ដូចនេះទាមទារឲ្យមានសមភាពរវាងសមាសភាពទាំងអស់ដែលមាននៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ប៉ុន្តែមិនមែនជាភាពងាយស្រួលនោះឡើយ។

សេរីភាព ការច្នៃប្រឌិត ភាពរស់រវើក គឺជាលក្ខណៈពិសេសនៃសេដ្ឋកិច្ចទីផ្សារសេរី ប៉ុន្តែផ្សា ភ្ជាប់ជាមួយកត្តានេះ រួមមានទាំងមូលហេតុដែលបង្កឲ្យមានភាពអនាធិបតេយ្យ ការរកស៊ីបោកប្រាស់ ភាពមិនសុចរិត និងការដណ្ដើមទុនគ្នាជាអាទិ៍ ត្រូវបានកើតមានឡើងក្នុងគោលដៅបំពេញនូវផលប្រយោជន៍រៀងខ្លួន ។ កត្តាទាំងនេះហើយ ជាមូលហេតុនិង លក្ខខណ្ឌនៃបទល្មើសផ្នែកសេដ្ឋកិច្ចមួយចំនួនកើតឡើងដូចជា ការរត់ពន្ធ ផលិតនិងលក់ទំនិញ ក្លែងក្លាយ ការឆបោក ការរំលោភលើទំនុកចិត្ត ។ល។ នៅពេលដែលសេដ្ឋកិច្ចជួបប្រទះនូវវិបត្តិ បទល្មើសមួយចំនួននឹងកើតឡើងដែរដូចជា៖ អំពើពុករលួយ ពេស្យាចារ ចោរកម្ម...។ល។

ទន្ទឹមនឹងនេះ កត្តាសេដ្ឋកិច្ចផ្ទាល់ខ្លួនក៏ជាមូលហេតុមួយដែលនាំឲ្យមានបទល្មើសផងដែរ ដូចជា៖ បញ្ហាទុរគត ភាពក្រីក្រ ដែលបង្ខំឲ្យពួកគេត្រូវតែប្រព្រឹត្តបទល្មើសដើម្បីបំពេញនូវក្រពះ និងសេចក្ដីត្រូវការរបស់ខ្លួន ។

**២.៣. កត្តានៃស្ថានភាពរបបនយោបាយ**

នយោបាយគឺជាការស្ដែងឡើង និងប្រមូលផ្ដុំនូវកត្តាសេដ្ឋកិច្ចនៅក្នុងទំនាក់ទំនងគ្នាទៅវិញទៅមករវាងបណ្ដាមនុស្សគ្រប់ស្រទាប់ក្នុងសកម្មភាពរបស់រដ្ឋ ។ នយោបាយផ្សារភ្ជាប់នឹងផលប្រយោជន៍សេដ្ឋកិច្ចហើយឆ្លុះបញ្ចាំងនូវផលប្រយោជន៍និងតម្រូវការរីកចម្រើនរបស់សេដ្ឋកិច្ច។ ការផ្លាស់ប្ដូររបបនយោបាយ អាចបង្កឲ្យមានការសម្រួលដល់មនោគមន៍វិជ្ជានៃការមិនទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ហើយធ្វើឲ្យគេមានការយល់ឃើញថាទង្វើទាំងអស់សុទ្ធតែជាការសម្ដែងមតិផ្នែកនយោបាយ ។ ឧ. ការសម្ដែងដែលជាការបរិហាកេរ្តិ៍ ជេរប្រមាថ ញុះញង់ឲ្យប្រព្រឹត្តបទល្មើសជាដើម។

**២.៤. កត្តាឥទ្ធិពលនៃសង្គ្រាម**

ប្រទេសជាច្រើនតែងទទួលរងឥទ្ធិពលអាក្រក់ពីសង្គ្រាម និងបានបន្សល់ទុកនូវបច្ច័យធ្ងន់ធ្ងរនៅក្នុងជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសឥទ្ធិពលដែលកើតចេញពីសង្គ្រាម

ដែលអូសបន្លាយក្នុងរយៈពេលវែង ។ សង្គ្រាមបានបំផ្លាញនូវរចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គម ធនធានធម្មជាតិ រួមទាំងធន ធានមនុស្ស ។ សេដ្ឋកិច្ចមិនមានស្ថេរភាព សង្គមមិនមានរបៀបរៀបរយ និងសណ្តាប់ធ្នាប់ ដូចនេះសមាសភាពមិនល្អ ឆ្លៀតប្រើប្រាស់ឧកាសនេះដើម្បីស្វែងរកផលប្រយោជន៍បុគ្គល ដើម្បីបម្រើឲ្យសេចក្តីត្រូវការហួសប្រមាណរបស់ខ្លួន ធ្វើមាន ធ្វើបានដោយមិនត្រឹមត្រូវ និងឈានចូលទៅក្នុងផ្លូវនៃការប្រព្រឹត្តបទល្មើស ។

**២.៥. កត្តានៃវប្បធម៌អប់រំ**

ប្រជាជាតិណាក៏ដោយក៏មានមោទនភាពចំពោះវប្បធមិនិងអរិយធមិរបស់ខ្លួន ប៉ុន្តែមិនមែនបដិសេធចំពោះបណ្តាវប្បធមិរបស់ប្រជាជាតិផ្សេងដែលមានលក្ខណៈល្អប្រសើរ ដែលកំពុងហូរចូល និងកំពុងមានឥទ្ធិពលមកលើនិងលាយឡំនៅក្នុងវប្បធមិរបស់ប្រជាជាតិមួយនោះផងទេ។ ប៉ុន្តែកត្តាមួយដែលគប្បីត្រូវពិចារណា គឺលំហូរចូលវប្បធមិមួយចំនួនដែលបង្កនូវភាពអសកម្មមួយចំនួនដល់សង្គមដូចជាការកាប់សម្លាប់មនុស្ស រំលោភសេពសន្ថវៈ ប្លន់ធនាគារ ប្លន់ទ្រង់ទ្រាយធំ ចាប់ជំរិត ដែលមួយចំនួននៃករណីនេះកើតចេញពីការទស្សនាភាពយន្ត ដែលមានសកម្មភាពឃោរ ឃៅ និង ភាពយន្តអាសអាភាសជាដើមដែកជំរុញនូវអារម្មណ៍ផ្លូវភេទ។

គ្រួសារ សាលារៀន និងមជ្ឈដ្ឋានសង្គម មានតួនាទីរួមគ្នាក្នុងការអប់រំមនុស្ស ដែលជាសមាជិកសង្គម ។ ភាពអវិជ្ជា សីលធមិរស់នៅមិនសមរម្យ ជាផលិតផលដែលកើតចេញពីភាពខ្វះការអប់រំ បានបង្កឲ្យមនុស្សមួយចំនួនធ្លាក់ចូលទៅក្នុងផ្លូវប្រព្រឹត្តបទល្មើសផងដែរ។

**២.៦. កត្តានៃប្រព័ន្ធច្បាប់**

ការកសាងនីតិរដ្ឋ ចាត់ទុកជាបញ្ហាចំបងនិងសំខាន់សម្រាប់ការគ្រប់គ្រងសង្គមជារួម និងដោយឡែកចំពោះការងារតស៊ូប្រឆាំងនិងបង្ការបទល្មើស ។ នៅក្នុងនីតិរដ្ឋ រាល់សកម្មភាពរបស់ស្ថាប័នរដ្ឋ សង្គមរួមទាំងពលរដ្ឋផងមានភាពសកម្មនិងឯកភាពគ្នាក្នុងការបំបាត់ចោលនូវបាតុភាពអសកម្មនានាដែលជាមូលដ្ឋាននៃភាពស្ថិតស្ថេរនិងរីកចំរើននៃបទល្មើស ។

ការប្រឆាំងនិងបង្ការបទល្មើសតែងតែផ្សារភ្ជាប់និងទាមទារឲ្យមានការគាំទ្រ ដោយកម្លាំងបង្ខិតបង្ខំរបស់ច្បាប់ ។ ម្យ៉ាងទៀតពលរដ្ឋអាចកំណត់បាននូវទិសដៅសកម្មភាពត្រឹមត្រូវរបស់ខ្លួនក្នុងជីវភាពសង្គមបានអាស្រ័យដោយមូលដ្ឋាននៃការកំណត់របស់ច្បាប់។ ការខ្វះចន្លោះភាពអន់ថយ ភាពប្រទាំងប្រទើសគ្នានៃច្បាប់នាំមកនូវភាពច្របូលច្របល់ក្នុងការកំណត់ និងវិនិច្ឆ័យអំពីអំពើល្មើសដែលកើតមានក្នុងសង្គម។

ការរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខសង្គមដោយច្បាប់ គឺជាស្ថានភាពបន្ទាប់សម្រាប់នីតិរដ្ឋ ហើយជាពិសេសក្នុងវិស័យតស៊ូប្រឆាំងនិងបង្កាបទល្មើស ។ ផ្ទុយទៅវិញភាព

ចន្លោះ ប្រហោង ភាពអន់ថយ និងកង្វះខាតច្បាប់ នឹងមានឥទ្ធិពលធ្វើឲ្យបញ្ហាបទល្មើសឈានឡើងដល់កម្រិតធ្ងន់ធ្ងរសម្រាប់សង្គម។

**២.៧. កត្តានៃស្ថាប័នការពារច្បាប់**

នៅបណ្តាប្រទេសខ្លះ នៅក្នុងអំឡុងពេលណាមួយនោះ បញ្ហាបទល្មើសបានឈានឡើងដល់ កម្រិតធ្ងន់ធ្ងរ ហើយសឹងតែមិនអាចគ្រប់គ្រងបាន ដែលជាហេតុបណ្តាលឲ្យមានការអន្តរាយធ្ងន់ធ្ងរ និងប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពលរដ្ឋទាំងផ្នែកសេដ្ឋកិច្ចនិងសុវត្ថិភាពឯកជន។ ភាពខ្វះខាត សមត្ថភាពរបស់ស្ថាប័នការពារច្បាប់ និងការសហការរវាងស្ថាប័នទាំងនោះ និងខ្វះភាពប្តូរផ្តាច់ក្នុង ការប្រឆាំងនឹងបទល្មើសជាហេតុនាំឲ្យមានការមើលស្រាលច្បាប់ពីសំណាក់ជនល្មើស រួមទាំងការ មើលស្រាលចំពោះស្ថាប័នការពារច្បាប់ផងដែរ។ មូលហេតុផ្សេងទៀតគឺកង្វះខាតនូវមធ្យោបាយ ប្រឆាំង បង្ការបទល្មើសដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងលក្ខណៈវិទ្យាសាស្ត្រដែលនាំមកនូវ ភាពអសកម្មក្នុងការបង្ក្រាបទល្មើស ។

ការប្រឆាំង និងបង្កាបទល្មើសទាមទារឲ្យមានផែនការសកម្មភាពដែលព្យាករណ៍ទុកជាមុន ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ។ បញ្ហាជាមូលដ្ឋានគឺការកំណត់នូវមូលហេតុនិងលក្ខខណ្ឌដែល នាំឲ្យមានបទល្មើស ។ សកម្មភាពរបស់ស្ថាប័នការពារច្បាប់ ចំណុះក្រោមសមត្ថភាពរបស់មន្ត្រីនៅ ក្នុងស្ថាប័ននោះ ។ លទ្ធផលនៃសកម្មភាពស៊ើបអង្កេត ការចោទប្រកាន់ ការជំនុំជំរះ អប់រំកែប្រែ ទណ្ឌិតទទួលបានលទ្ធផលគាប់ប្រសើរអាស្រ័យដោយសមត្ថភាព សីលធម៌និងភាពប្តូរផ្តាច់របស់ មន្ត្រីមាមសមត្ថកិច្ចនោះ ។ ប្រសិនបើពុំបានយកចិត្តទុកដាក់ចំពោះបញ្ហាខាងលើនោះការងារ ប្រឆាំងនិងបង្កាបទល្មើសនឹងជួបប្រទះនូវឧបសគ្គជាមិនខាន ។

**២.៨. កត្តានៃទីតាំងភូមិសាស្ត្រ**

ទីតាំងភូមិសាស្ត្រមានឥទ្ធិពលផងដែរចំពោះបញ្ហាបទល្មើស ។ រវាងទីក្រុង ជនបទ តំបន់ព្រៃភ្នំ វាលទំនាប ស្ថានភាពនៃបទល្មើសមានលក្ខណៈនិងការវិវត្តន៍ខុសគ្នា ។ បទល្មើសមួយចំនួនអាច កើតឡើងអាស្រ័យដោយស្ថានភាពទីតាំងភូមិសាស្ត្រ ដូចជាការកាប់ព្រៃខុសច្បាប់ អាចកើតមាន ឡើងនូវតំបន់មានព្រៃឈើ បទល្មើសនេសាទអាចកើតមាននៅតំបន់មានទន្លេបឹងបួរ ស្ទឹងព្រែក ។ ការកកស្ទះចរាចរណ៍នាំឲ្យមានគ្រោះថ្នាក់ចរាចរណ៍ ទីកន្លែងស្ងាត់ជាការគាប់ប្រសើរសម្រាប់បទ ល្មើសសេពសន្ថវៈជាដើម។

# សេចក្តីសន្និដ្ឋាន

ជារួមមកដើម្បីអាចចាត់ទុកថាអំពើមួយជាបទល្មើស លុះត្រាតែអំពើទាំងនោះបង្កនូវព្យសនកម្មដល់អ្នកដទៃដោយអំពើនោះផ្ទាល់ ហើយអ្នកប្រព្រឹត្តអំពើល្មើសនោះត្រូវទទួលទណ្ឌកម្មដែលបានកំណត់ទុកនូវក្នុងច្បាប់ ហើយបទល្មើសត្រូវតែមានចែងទុកជាមុននៅក្នុងច្បាប់។ លើសពីនេះទៀតបទល្មើសអាចកើតមានឡើងក្នុងសង្គមបានដោយសារតែកត្តាជុំវិញជាច្រើនចូលរួម មានកត្តាខាងក្នុងរបស់ជនល្មើសផ្ទាល់និងកត្តាខាងក្រៅដែលជាកត្តាជំរុញឲ្យជនល្មើសប្រព្រឹត្តនូវបទល្មើស ។ សង្គមគ្រួសារដែលអ័ព្វអួរ ការអូសទាញ និង ការសេពគប់នូវមិត្តភក្តិមិនល្អ ភាពក្រីក្រ ការកេងប្រវ័ញ្ចគ្នាទៅវិញទៅមកក្នុងពេលសេដ្ឋកិច្ចមានការប្រែប្រួលជាដើមនោះ សុទ្ធតែជាកត្តានាំមកនូវការកើតឡើងនូវបទល្មើស ។

ដើម្បីបង្ការនិងកាត់បន្ថយនូវបទល្មើសនៅក្នុងសង្គមនៃប្រទេសនីមួយៗ ឧក្រិដ្ឋវិទ្យាដើរតួនាទីយ៉ាងសំខាន់និងចាំបាច់បំផុតជាជំនួយដល់ច្បាប់ព្រហ្មទណ្ឌ។ ដោយហេតុថាការសិក្សាឧក្រិដ្ឋវិទ្យាគឺការសិក្សាទៅលើមូលហេតុក៏ដូចជាកត្តាដែលនាំឲ្យមានបទល្មើសកើតឡើង ហេតុនេះនៅពេលដែលយើងដឹងពីមូលហេតុទាំងនេះហើយ យើងអាចរកនូវវិធីដើម្បីទប់ស្កាត់កុំឲ្យបទល្មើសកើតឡើងបាន ។ នេះជាតួនាទីដ៏សំខាន់របស់ស្ថាប័នជំនាញទាំងឡាយដែលពាក់ព័ន្ធនឹងឧក្រិដ្ឋវិទ្យានិងការរួមសហការគ្នាយ៉ាងស្អិតរមួតពីបុគ្គលដែលស្ថិតក្នុងតួនាទីខ្លួនផងដែរ។ ទន្ទឹមនឹងនេះ ឧក្រិដ្ឋនិច្ឆ័យវិទ្យាក៏មានតួនាទីយ៉ាងសំខាន់ និងចាំបាច់នៅក្នុងការស្វែងរកបទល្មើសដ៏មានប្រសិទ្ធភាពមួយនិងត្រូវបានប្រើក្នុងការបង្ការបទល្មើសផងដែរ ដោយហេតុថាឧក្រិដ្ឋនិច្ឆ័យជាប្រព័ន្ធប្រមូលផ្តុំនៃការយល់ដឹងខាងផ្នែកស៊ើបរកបទល្មើស ជាការបង្ហាញឲ្យឃើញនូវធាតុផ្សំនៃបទល្មើសពាក់ព័ន្ធនិងការកំណត់នូវអត្តសញ្ញាណជនល្មើស។

# ឯកសារយោង


បណ្ឌិត ស៊ិន រិទ្ធ, ឧក្រិដ្ឋវិទ្យាឆ្នាំ២០១១, KhmerFamous.com ។

ច្បាប់ព្រហ្មទណ្ឌ, ក្រសួងឧត្តមសិក្សា និង បច្ចេកទេស មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

www.studymode.com/subjects/crimonology-case-study-page1.html

http://england.shelter.org.uk/get_advice/antisocial_behaviour/eviction_for_antisocial_behaviour

homepages.rpi.edu/~verwyc/lawchap5.htm